ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតមជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

----

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ១៣ សសរ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## សម្រេច

ប្រការ ១: ត្រូវបានបង្កើត មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល ជាសេនាធិការឱ្យគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ សំដៅប្រតិបត្តិការបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងប្រទេស និងចូលរួមបេសកកម្មថែរក្សាសន្តិភាព អ.ស.ប និងហ្វឹកហ្វឺនកងកំលាំងត្រៀមចេញបេសកកម្ម ។

/1

**ប្រការ ២:** មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាលមានបេសកកម្ម តួនាទី និងភារកិច្ច ដូចខាងក្រោម :

- រៀបចំផែនការសកម្មភាពការងាររបស់ខ្លួនរយៈពេលខ្លី មធ្យម និងវែង សំរាប់ប្រតិបត្តិការបោសសំអាតមីន យុទ្ធភ័ណ្ឌ មិនទាន់ផ្ទុះនៅក្នុងប្រទេស និងចូលរួមបេសកកម្មថែរក្សាសន្តិភាព អ.ស.ប និងហ្វឹកហ្វឺនកងកំលាំង ត្រៀមចេញបេសកកម្ម ដោយមានការជួយឧបត្ថម្ភពីក្រៅក្នុង និងក្រៅប្រទេស ស្របតាមស្តង់ដារមីនជាតិ និងអន្តរជាតិ ដើម្បីពង្រឹង ពង្រីកនូវសមត្ថភាព គុណភាព ដូចបណ្តាប្រទេសដទៃ ។
- រៀបចំគោលការណ៍សិក្សាស្រាវជ្រាវ ពិនិត្យ កែសំរួលនូវមុខជំនាញទាំងក្នុង និងក្រៅប្រទេស ធ្វើយ៉ាងណាឱ្យ សមស្របតាមសំណូមពររបស់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ជាពិសេស អ.ស.ប ។
- សិក្សាស្រាវជ្រាវ ដោយអនុវត្តតាមកម្មវិធីការយល់ដឹងគ្រោះថ្នាក់មីន រុករកគ្រាប់មីន ពត៌មានស្តីពីការកំណត់ ទីតាំង ផែនទីចំការមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការបោសសំអាតមីន រួមទាំងការកំទេចគ្រឿងផ្ទុះ និង ការហ្វឹកហ្វឺនជាក់ស្តែងក្នុងសកម្មភាពមីន ។
- ចាត់វិធានការណ៍យ៉ាងហ្មឹងម៉ាត់ ដើម្បីធានាសុវត្ថិភាពកំរិតខ្ពស់បំផុត ឱ្យដល់បុគ្គលិកទាំងអស់របស់ មជ្ឈមណ្ឌលក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។
- តាមដាន និងត្រួតពិនិត្យការងារនៃសកម្មភាពដោះបំផ្លាញមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដើម្បីឱ្យគ្រប់ កងឯកភាព នៃកងយោធពលខេមរភូមិន្ទ ដែលជាប្រតិបត្តិករអនុវត្តស្របតាមយុទ្ធសាស្ត្រ ផែនការរបស់ រាជរដ្ឋាភិបាល ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ។
- ជំរុញការរៀបចំឯកសារ ទិន្នន័យ វិភាគ ប្រៀបធៀបអំពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅទូទាំងប្រទេស និងនៅប្រទេសដទៃដែលមានមីន ដោយសហការជាមួយអាជ្ញាធរមីនកម្ពុជា និងអង្គភាពប្រតិបត្តិករផ្សេងៗ ដើម្បីធានាបានប្រសើរក្នុងការអនុវត្តន៍ភារកិច្ចបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅកម្ពុជា និងក៏ ដូចជា ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប ។
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់គ្រប់កងឯកភាពកងទ័ព ដែលបានហ្វឹកហ្វឺន បណ្តុះបណ្តាលបច្ចេកទេសកំចាត់ មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅទូទាំងកងយោធពលខេមរភូមិន្ទ ។
- ទំនាក់ទំនងល្អជាមួយអាជ្ញាធរមីនកម្ពុជា អង្គភាពប្រតិបត្តិករជាតិ និងអន្តរជាតិ ក្រសួង ស្ថាប័ន និងអាជ្ញាធរ ដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីសហការ និងដោះស្រាយនូវរាល់មូលដ្ឋានថវិកា សំភារៈ ឧបករណ៍ មធ្យោបាយ សំរាប់បំរើការឱ្យការងារជំនាញរបស់មជ្ឈមណ្ឌល ។
- សហការយ៉ាងជិតស្និទជាមួយបណ្តាប្រទេសនានា ក្នុងការទំនាក់ទំនងការងារជំនាញរបស់មជ្ឈមណ្ឌល ស្វះ ស្វែងរកប្រភពជំនួយសំភារៈ បច្ចេកទេស និងហិរញ្ញវត្ថុ ក៏ដូចជាការផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាពីគ្នាទៅ វិញទៅមក ឱ្យមានភាពរលូន និងផ្លែផ្កា ។

- អនុវត្តយ៉ាងតឹងរឹងបំផុត នូវច្បាប់ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងនឹងមនុស្ស និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងអនុសញ្ញាអូតាវ៉ា ស្តីពីការហាមប្រាមការប្រើប្រាស់ រក្សាទុក ផលិតមីនប្រឆាំងមនុស្ស នៅទូទាំងកងយោធពលខេមរភូមិន្ទ ។
- គ្រប់គ្រង រំសេវជាតិផ្ទុះគ្រប់ប្រភេទ សំរាប់បំរើឱ្យការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ប្រកបដោយប្រសិទ្ធភាព ។
- ដឹកនាំ និងសហការជាមួយបណ្តាប្រភេទទ័ព ទ័ពជំនាញ យោធភូមិភាគ កងពលរហូតដល់តំបន់ប្រតិបត្តិការ សឹករងខេត្ត ក្រុង ក្នុងការបំរើសកម្មភាពបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងធ្វើជាសេនាធិការក្នុងការបូកសរុបរួមពីសកម្មភាពបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៃ ខ.ភ.ម ។

**ប្រការ ៣:** មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល មានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម ឧត្តមសេនីយទោ សែម សុវណ្ណនី អគ្គលេខាធិការរង អាជ្ញាធរមីនកម្ពុជា និងជាមេបញ្ជាការរងវិស្វកម្មអគ្គបញ្ជាការ នៃខ.ភ.ម. — ប្រធាន

២. ឯកឧត្តម ឧត្តមសេនីយទោ សួង ឃុន្នី មេបញ្ជាការរង វិស្វកម្មអគ្គបញ្ជាការ នៃខ.ភ.ម. — អនុប្រធាន

៣. វរសេនីយ៍ឯក គួច ផេងទន់ នាយរងសេនាធិការ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ នៃ ខ.ភ.ម. ទទួលបន្ទុកប្រតិបត្តិការ — សមាជិក

៤. វរសេនីយ៍ឯក អ៊ុំ វ៉ាន់ថា នាយរងសេនាធិការ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ នៃខ.ភ.ម. ទទួលបន្ទុករដ្ឋបាល-បុគ្គលិក ទំនាក់ទំនងសាធារណៈ ពតិមាន និងអធិការកិច្ច — សមាជិក

៥. វរសេនីយ៍ឯក តាំង សំបិន នាយកសាលាវិស្វកម្ម បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការនៃខ.ភ.ម.ទទួលបន្ទុកជានាយកសាលាហ្វឹកហ្វឺនបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាលផ្នែកប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប — សមាជិក

៦. វរសេនីយ៍ទោ អោក ស្មៀង នាយរងការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ នៃ ខ.ភ.ម. ទទួលបន្ទុកភស្តុភារ-ហិរញ្ញវត្ថុ — សមាជិក

៧. វរសេនីយ៍ទោ តន់ សាលី នាយរងការិយាល័យ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ នៃខ.ភ.ម. ទទួលបន្ទុកសំភារៈ-បច្ចេកទេស — សមាជិក

៨. វរសេនីយ៍ទោ អ៊ុន ពីឌីច នាយរងការិយាល័យសំណង់ យុទ្ធសាស្ត្រ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការនៃខ.ភ.ម. ទទួលបន្ទុកផែនការ ស្រាវជ្រាវ ទិន្នន័យ និងត្រួតពិនិត្យ — សមាជិក

មជ្ឈមណ្ឌល មានជំនាញការជាតិ ឬអន្តរជាតិមួយចំនួន ជាជំនួយការបច្ចេកទេស តាមការចាំបាច់ ។ ភារកិច្ចរបស់ផ្នែកនីមួយៗ និងសាលាហ្វឹកហ្វឺន នឹងត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានមជ្ឈមណ្ឌល ។

**ប្រការ ៤:** មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល មានត្រាមួយដោយឡែក និងមានកញ្ចប់ថវិកាក្នុងថវិការរបស់គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

សាលាហ្វឹកហ្វឺនបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាលផ្នែកប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប មានទីតាំងនៅឧត្តុង្គ ( អតីតសាលាវិស្វកម្ម) ។

មជ្ឈមណ្ឌល ទំនាក់ទំនងរកប្រភពជំនួយពីបណ្តាប្រទេសផ្សេងៗ អង្គការជាតិ និងអន្តរជាតិ ។ មជ្ឈមណ្ឌលអាចរកប្រាក់កំរៃពីសេវាកម្មផ្សេងៗ ផ្តល់ដោយអង្គការសាធារណៈ និងឯកជន ។

**ប្រការ ៥:** បុគ្គលិកក្របខ័ណ្ឌដែលបំរើការក្នុងមជ្ឈមណ្ឌល មានប្រភពមកពីកងយោធពលខេមរភូមិន្ទ និងអាចជាបុគ្គលិកជាប់កិច្ចសន្យារបស់មជ្ឈមណ្ឌល លើកលែងតែមានតំរូវការអ្នកជំនាញ ដូចជាកុំព្យូទ័រ ឬជំនាញផ្សេងទៀត ទើបអនុញ្ញាតស្នើសុំក្របខ័ណ្ឌថ្មី នៃ ខ.ភ.ម ។

នាយទាហាន ពលទាហានដែលត្រូវជ្រើសរើសមកហ្វឹកហ្វឺនត្រូវផ្ទេរជីវភាពមកមជ្ឈមណ្ឌលដើម្បីធ្វើការធានាបន្ត ។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ ៦
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ